# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៤៩៩ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរ និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** ៖ ផ្ទេរ និងតែងតាំងមុខតំណែងនាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ចំនួន ០៤ រូប នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម ៖

១- លោកឧត្តមសេនីយ៍ឯក **តាន់ សំណាង** អត្តលេខ ៩៦០៦២ ជាអគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ

២- លោកឧត្តមសេនីយ៍ទោ **ហែម សុខន្តិ** អត្តលេខ ៦៦៥០៣ ពីអគ្គនាយករងនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ទៅជាអគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ

៣- លោកឧត្តមសេនីយ៍ទោ **លឹម ដាឆុង** អត្តលេខ ០៣៥១៨ ជាអនុប្រធានសេនាធិការដ្ឋាន

៤- លោកឧត្តមសេនីយ៍ត្រី **ឡុយ ប៉ា** អត្តលេខ ៨៥១១២ ជាអនុប្រធានសេនាធិការដ្ឋាន។

**មាត្រា ២ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ព្រហ ៣ កើត ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជក្រឹត្យ

នស/រកត/១១២៣/ ៤៤១១

ស្តីពី

# ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមមេធាវីរាជរដ្ឋាភិបាល

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០៧៤ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងនិងផ្តល់ឋានៈសមាសភាពមេធាវីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើតក្រុមមេធាវីរាជរដ្ឋាភិបាល ដែលសរសេរជាអក្សរកាត់ថា **ក.ម.រ.** ជាអង្គភាពអមទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីជួយកិច្ចការច្បាប់ ការពារសិទ្ធិ និងផលប្រយោជន៍ជូនថ្នាក់ដឹកនាំជាតិ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## ជំពូកទី២
## តួនាទីនិងភារកិច្ចរបស់ ក.ម.រ.

**មាត្រា២.-**

**ក.ម.រ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ជាតំណាងស្របច្បាប់ក្នុងការការពារសិទ្ធិ និងផលប្រយោជន៍ជូនថ្នាក់ដឹកនាំជាតិ រាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នចំណុះរាជរដ្ឋាភិបាល នៅចំពោះមុខយុត្តាធិការជាតិ អន្តរជាតិ
- ចូលរួមអនុវត្តគោលនយោបាយជាមួយរាជរដ្ឋាភិបាលក្នុងការលើកកម្ពស់វិស័យយុត្តិធម៌នៅកម្ពុជា
- ទទួលពិនិត្យ ស្រាវជ្រាវនូវរាល់ពាក្យបណ្ដឹង ដែលបានប្ដឹងសុំការអន្តរាគមន៍ពីរាជរដ្ឋាភិបាល
- ពិនិត្យលើកសំណើនិងផ្ដល់យោបល់ពាក់ព័ន្ធនឹងផលប្រយោជន៍របស់រាជរដ្ឋាភិបាលជូននាយករដ្ឋមន្ត្រី
- ចូលរួមពិនិត្យនិងផ្ដល់យោបល់លើកិច្ចសន្យារដ្ឋបាលនិងកិច្ចព្រមព្រៀងផ្សេងៗ របស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ
- ធ្វើរបាយការណ៍ប្រចាំឆ្នាំអំពីសកម្មភាពការងាររបស់ **ក.ម.រ.** ជូននាយករដ្ឋមន្ត្រី
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ពីនាយករដ្ឋមន្ត្រី។

## ជំពូកទី៣
## សមាសភាពរបស់ ក.ម.រ.

**មាត្រា៣.-**

**ក.ម.រ.** មានប្រធាន១(មួយ)រូបនិងមានសមាជិកមួយចំនួន តាមការចាំបាច់។

សមាសភាពក្រុមមេធាវីរាជរដ្ឋាភិបាលត្រូវតែងតាំងនិងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្ដីស្នើសុំពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី។

**មាត្រា៤.-**

មេធាវីដែលអាចត្រូវបានជ្រើសតាំងឱ្យបំពេញមុខងារជាប្រធាននិងជាសមាជិក **ក.ម.រ.** ត្រូវមានលក្ខណសម្បត្តិ ដូចខាងក្រោម ៖

- ប្រធាន **ក.ម.រ.** ជាមេធាវីពេញសិទ្ធិ ដែលបានប្រកបវិជ្ជាជីវៈ យ៉ាងតិច១០(ដប់)ឆ្នាំ
- សមាជិក **ក.ម.រ.** ជាមេធាវីពេញសិទ្ធិ ដែលបានប្រកបវិជ្ជាជីវៈ យ៉ាងតិច៥(ប្រាំ)ឆ្នាំ
- មានសមត្ថភាព ចំណេះដឹងទូលំទូលាយ និងបទពិសោធន៍ការងារ ព្រមទាំងមានសីលធម៌ល្អ។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ ក.ម.រ.

**មាត្រា៥.-**

ប្រធាន **ក.ម.រ.** មានភារកិច្ចដឹកនាំ គ្រប់គ្រង និងចាត់ចែងការងាររួមរបស់ **ក.ម.រ.**។

ប្រធាន **ក.ម.រ.** អាចចាត់តាំងឬប្រគល់សិទ្ធិជូនសមាជិកណាម្នាក់ឬច្រើននាក់ ជាតំណាងទទួលបន្ទុកកិច្ចការណាមួយ។

នៅពេលដែលប្រធាន **ក.ម.រ.** អវត្តមាន ឬមានករណីចាំបាច់ ប្រធាន **ក.ម.រ.** អាចប្រគល់សិទ្ធិជូនសមាជិក **ក.ម.រ.** ណាម្នាក់ ឱ្យទទួលដឹកនាំការងារប្រចាំថ្ងៃរបស់ **ក.ម.រ.** ក្នុងឋានៈជាប្រធានស្ដីទីរហូតដល់មានវត្តមានប្រធាន **ក.ម.រ.**។

**មាត្រា៦.-**

សមាជិក **ក.ម.រ.** ត្រូវអនុវត្តការងារតាមការកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន **ក.ម.រ.**។

សន្និបាត **គ.ម.រ.** ធ្វើឡើង២(ពីរ)ដងក្នុងមួយឆ្នាំ។ ក្នុងករណីចាំបាច់ **គ.ម.រ.** អាចប្រជុំជា វិសាមញ្ញតាមការកោះអញ្ជើញរបស់ប្រធាន **គ.ម.រ.**។

**គ.ម.រ.** ត្រូវមានបទបញ្ជាផ្ទៃក្នុង ដើម្បីជានាដល់កិច្ចដំណើរការការងារ និងការកំណត់អំពីទណ្ឌកម្មខាងវិន័យ។

**មាត្រា៧.-**

**គ.ម.រ.** អាចអញ្ជើញមន្ត្រីជំនាញពីក្រសួងស្ថាប័នពាក់ព័ន្ធ ចូលរួមប្រជុំពិភាក្សាការងារបច្ចេកទេសក្នុងករណីពាក់ព័ន្ធនឹងបណ្ដឹង ឬករណីចាំបាច់ណាមួយ។

ដើម្បីប្រសិទ្ធភាពការងារ **គ.ម.រ.** អាចធ្វើសំណើឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ ផ្ដល់ឯកសារ ទិន្នន័យ និងព័ត៌មាននានា ដែលទាក់ទងនឹងសំណុំរឿង ឬករណីចាំបាច់ណាមួយ។

**មាត្រា៨.-**

**គ.ម.រ.** អាចជួលទីប្រឹក្សាបច្ចេកទេសមួយចំនួនតាមការចាំបាច់។

**មាត្រា៩.-**

**គ.ម.រ.** មានលេខាធិការដ្ឋានជាសេនាធិការសម្រាប់ដំណើរការការងារប្រចាំការ។

លេខាធិការដ្ឋាននៃ **គ.ម.រ.** ដឹកនាំដោយ ប្រធាន១(មួយ)រូប មានអនុប្រធាន និងសមាជិកមួយចំនួនតាមការចាំបាច់។

ប្រធានលេខាធិការដ្ឋាននៃ **គ.ម.រ.** ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី។

អនុប្រធាននិងសមាជិកលេខាធិការដ្ឋាននៃ **គ.ម.រ.** ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់ប្រធាន **គ.ម.រ.**។

ក្នុងករណីចាំបាច់ ប្រធាន **គ.ម.រ.** អាចស្នើជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាជាអ្នកជំនាញឱ្យជួយការងាររបស់លេខាធិការដ្ឋាននៃ **គ.ម.រ.**។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **គ.ម.រ.** ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១០.-**

**គ.ម.រ.** មានរូបសញ្ញា និងត្រាដោយឡែកសម្រាប់ដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន។

គំរូរូបសញ្ញារបស់ **គ.ម.រ.** ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃព្រះរាជក្រឹត្យនេះ។

គំរូត្រារបស់ **គ.ម.រ.** ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃព្រះរាជក្រឹត្យនេះ។

**មាត្រា១១.-**

ប្រាក់បំណាច់មុខងារនិងអត្ថប្រយោជន៍ផ្សេងទៀតរបស់ប្រធាន សមាជិក និងមន្ត្រីលេខាធិការដ្ឋាន **គ.ម.រ.** ត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

## ជំពូកទី៥
## ប្រភពធនធានរបស់ គ.ម.រ.

**មាត្រា១២.-**

**គ.ម.រ.**មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ដែលជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី។

**គ.ម.រ.** មានសិទ្ធិទទួល គ្រប់គ្រង ចាត់ចែងនិងប្រើប្រាស់ តាមនីតិវិធីហិរញ្ញវត្ថុជាធរមាននូវធនធានដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ និងពីប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់បំពេញភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា១៣.-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយណា ដែលពាក់ព័ន្ធនឹងការតែងតាំងប្រធាននិងសមាជិកក្រុមមេធាវីរាជរដ្ឋាភិបាល ត្រូវមានអានុភាពអនុវត្តបន្តទៀតរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៥.-**

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ ពុធ ១០រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០២៣

**នរោត្តម សីហមុនី**

នសរ.២៣១១.៤៥៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**ឧបសម្ព័ន្ធទី១ នៃព្រះរាជក្រឹត្យលេខ ៥៤១១ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២៣**

**ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមមេធាវីរាជរដ្ឋាភិបាល**

**គំរូរូបសញ្ញារបស់ ក.ម.រ.**

អត្ថន័យនៃរូបសញ្ញា
ក្រុមមេធាវីរាជរដ្ឋាភិបាល

១- រូបសញ្ញាចំកណ្តាលភ្ជាប់ដោយជញ្ជីងពីរស្មើគ្នា ពណ៌ខៀវចាស់ តំណាងឱ្យមនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់។

២- ផ្ទៃពណ៌ស ផ្នែកខាងក្នុង មានរាងជារង្វង់មូល និងអក្សរពណ៌ស តំណាងឱ្យភាពស្អាតស្អំ។

៣- ផ្ទៃពណ៌ខៀវចាស់ ផ្នែកខាងក្រៅ មានរាងជារង្វង់មូល និងអក្សរពណ៌ខៀវចាស់ តំណាងឱ្យភាពស្មោះត្រង់ ភាពជឿជាក់ និងអង់អាចក្លាហាន។

៤- **ក.ម.រ.** ជាអក្សរកាត់ តំណាងឱ្យក្រុមមេធាវីរាជរដ្ឋាភិបាល។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**ឧបសម្ព័ន្ធទី២ នៃព្រះរាជក្រឹត្យលេខ ៤៤១១ ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០២៣**
**ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមមេធាវីរាជរដ្ឋាភិបាល**

**គំរូត្រារបស់ ក.ម.រ.**

ក្រុមមេធាវីរាជរដ្ឋាភិបាល

ក.ម.រ.

ROYAL GOVERNMENT ATTORNEY GROUP

ROYAUME DU CAMBODGE

LE MINISTRE DU PALAIS ROYAL